## យុត្តាធិការយោធា (Courts Martial)

វាជាយុត្តាធិការរបស់តុលាការយោធា មានសមត្ថកិច្ច រាប់ទាំងទៅលើទាហានជើងគោក និងជើងទឹក។ តុលាការយោធាប្រទេសខ្លះ បានរៀបចំជាក្បួន (manual for Court Martial) ជាយូរមកហើយ ជាក់ស្តែងក្នុងសហរដ្ឋអាមេរិកតាំងពីឆ្នាំ ១៨០៦។

នាពេលបូរាណ តុលាការនេះ មានយុត្តាធិការទូលាយ គ្របលើទាហានដែលប្រព្រឹត្តបទល្មើសស៊ីវិល (មិនមែនបំពានវិន័យយោធា) និងមិនមានការធានាសិទ្ធិជនជាប់ចោទជាទាហាន ដូចជនជាប់ចោទជាជនស៊ីវិលទេ។ ក៏ប៉ុន្តែ នៅដើមសតវត្សទី២០ មានការកែទម្រង់ ហើយយុត្តាធិការ និងដំណើរនីតិវិធី មានលក្ខណៈស្រដៀងនឹងតុលាការធម្មតា ដូចជា ការធានាសិទ្ធិជនជាប់ចោទ (defendants' rights) ស្តង់ដាភស្តុតាង (standard of proof) និងនីតិវិធីដាក់ទោសទណ្ឌ (sentence)។ នេះដោយសារ ការជះឥទ្ធិពល នៃការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។

ក៏ប៉ុន្តែ វាក៏នៅមានបញ្ហាខ្លះ ដោយរដ្ឋខ្លះ បានពន្លាតនូវយុត្តាធិការយោធា គ្របដល់ជនស៊ីវិល (ប្រទេសបារាំង អាឡឺម៉ង់ ជាដើម) ហើយដែលការវិនិច្ឆ័យរបៀបនោះ បង្កជាបញ្ហាអយុត្តិធម៌ កើតឡើងដោយសារ គម្លាតនៃសមភាគរវាងភាគី (equality of arms) ក្នុងដំណើរការក្តីជាដើម (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 283-284)។